សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៤៤ ខែមិថុនា-កក្កដា ឆ្នាំ២០០៩
Issue: 44 June-July 2009

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# សហព្រះរាជអាជ្ញាអន្តរជាតិប្រកាសលាឈប់ពី សាលាក្តីខ្មែរក្រហម

## International Co-Prosecutor Declares Resignation from the Khmer Rouge Tribunal



*លោក រ៉ូប៊ឺត ពើទីត*

លោក **រ៉ូប៊ឺត ពើទីត** សហព្រះរាជអាជ្ញាអន្តរជាតិ (ជនជាតិកាណាដា) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមបានថ្លែងបញ្ជាក់ប្រាប់សាធារណជនថា លោកបានដាក់ពាក្យ សុំលាលែងពីការងាររបស់លោករួចហើយ ហើយការប្រកាសសុំលាលែងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ ខាងមុខនេះ នៅឯសន្និសីទសារព័ត៌មានមួយ ដែលបានរៀបចំឡើងដោយការិយាល័យ កិច្ចការសាធារណៈ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៩ កន្លងមកនេះ។ នៅក្នុងសន្និសីទនេះ លោកបានលើកឡើងថា *"ការសុំលាលែងនេះ ធ្វើឡើងដោយសារតែលោកមានមូលហេតុផ្ទាល់ខ្លួនចាំបាច់ និង បញ្ហាគ្រួសាររបស់លោកនៅប្រទេសកាណាដា"* ហើយថា ការលាលែងនេះ មិនមានអ្វីប៉ះពាល់ដល់ការងាររបស់លោកក្នុងអង្គជំនុំជម្រះវិសាមញ្ញ នោះឡើយ។

លោក **រ៉ូប៊ឺត ពើទីត** បានថ្លែងបន្ថែមថា ការពិតការសំរេចចិត្តលាឈប់ពីការងារដ៏ឧត្តុង្គឧត្តម ជាសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសាលាក្តីនេះ គឺជាការគួរឱ្យសោកស្តាយមួយ ប៉ុន្តែទទ្ទឹមនឹងនេះ លោកបាននិយាយថា វាក៏ជាការសំរេចចិត្តដ៏ត្រឹមត្រូវមួយផងដែរ ដោយសារតែបញ្ហាផ្ទាល់ខ្លួន និងគ្រួសាររបស់លោក ដែលចាំបាច់តម្រូវឱ្យលោកត្រូវតែលាឈប់ពីការងារនេះនៅប៉ុន្មានខែខាងមុខនេះ។

ជុំវិញបញ្ហាការសំរេចចាកចេញដោយភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិរូបនេះ ក៏មានក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការឃ្លាំមើលយ៉ាងដិតដល់ អំពីដំណើរការសាលាក្តីខ្មែរក្រហមបានបង្ហាញនូវក្តីកង្វល់ និងការសោកស្តាយផងដែរ។ ក្រុមអង្គការនេះ បានចេញសេចក្តីថ្លែងការណ៍រួមដោយបានគូសបញ្ជាក់នូវការព្រួយបារម្ភថា: ការចាកចេញនេះបង្កើតឱ្យមានភាពអវត្តមាន នៃតួនាទីដឹកនាំ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា, បណ្តោយឱ្យបញ្ហាខ្វែងគំនិតគ្នា រវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ទៅលើការសំរេចចោទប្រកាន់ជនសង្ស័យបន្ថែមមិនត្រូវបានដោះស្រាយ, រំខានដល់កិច្ចខិតខំប្រឹងប្រែងជំរុញដំណើរការកាត់សេចក្តីទៅមុខ និងបញ្ចប់សំណុំរឿង ០០២ ឱ្យបានពេញលេញ និងទាន់ពេលវេលា ព្រមទាំងបញ្ហាប៉ះពាល់ដល់គំនិតផ្តួចផ្តើមអំពីបញ្ហាកេរដំណែលរបស់តុលាការ ដែលលោក **រ៉ូប៊ឺត ពើទីត** បានផ្តួចផ្តើមកន្លងមកជាដើម។ ទន្ទឹមនឹងនេះដែរ អង្គការសង្គមស៊ីវិលទាំងនេះ ក៏បានឆ្លៀតធ្វើការអំពាវនាវដល់អង្គការសហប្រជាតិឱ្យជ្រើសរើសតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិថ្មី ដែលមានឯករាជ្យភាព និងមានបទពិសោធន៍ការងារល្អ ក្នុងការមកជំនួស លោក **រ៉ូប៊ឺត ពើទីត** ដើម្បីធានាថា ការងារដ៏សំខាន់របស់សាលាក្តីកូនកាត់នេះមិនត្រូវបានពន្យារ ឬក៏មិនត្រូវធ្វើឱ្យប៉ះពាល់នូវគុណភាពការងារផងដែរ។

ប៉ុន្តែជាមួយនឹងការព្រួយបារម្ភមួយចំនួនទាំងនេះ លោកបានពន្យល់តបថា នៅក្នុងការិយាល័យរបស់លោក ក៏មានលោកស្រី **ជា លាង** ជាសហព្រះរាជអាជ្ញាជាតិ និងលោក **វីល្លៀម ស្មីត** ដែលជាព្រះរាជអាជ្ញារងអន្តរជាតិ និងអ្នកផ្សេងទៀតនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា នឹងបន្តធ្វើការងាររួមជាក្រុម។ ដូចនេះ បញ្ហាដែលថា ការចាក ចេញរបស់លោកនាពេលនេះ នឹងអាចប៉ះពាល់ដល់ការងារ ជាពិសេសនៅខណៈពេលមានដំណើរការកាត់សេចក្តី ទៅលើអតីតប្រធានគុកទួលស្លែង **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** គឺមិនមែនដូចនោះទេ ដោយសារតែក្រុមការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា នៅតែបន្តធ្វើការរបស់ខ្លួនយ៉ាងសកម្មក្នុងការធ្វើការចោទប្រកាន់ ទៅលើ

ជនជាប់ចោទ។ ហើយម្យ៉ាងទៀត ជាមួយនឹងនាចាកចេញនេះ លោកក៏សង្ឃឹមថា ដំណើរការជ្រើសរើសព្រះរាជអាជ្ញាថ្មីជំនួស នឹងធ្វើទាន់ពេលមុនពេលវេលាចាកចេញរបស់លោក។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានមជ្ឈដ្ឋានខ្លះបានសំដែងការយល់ឃើញ និងសង្ស័យថា ការសម្រេចសុំលាឈប់របស់លោក **រ៉ូប៊ឺត ពើទីត** អាចបណ្ដាលមូលហេតុផ្សេង ព្រោះថា នាពេលកន្លងមក មានការលើកឡើងនូវការខ្វែងគំនិតគ្នា រវាងភាគីសហព្រះរាជអាជ្ញាអន្តរជាតិ និងភាគីព្រះរាជអាជ្ញាខ្មែរនៅក្នុងរឿងសំរេចចោទប្រកាន់ជនសង្ស័យខ្មែរក្រហមបន្ថែមទៀត ដែលរហូតមកទល់ពេលនេះ បណ្ដឹងឧទ្ធរណ៍អំពីបញ្ហានេះនៅមិនទាន់ត្រូវបានអង្គបុរេជំនុំជម្រះបើកការជំនុំជម្រះនៅឡើយ។

គួរបញ្ជាក់បន្ថែមថា លោក **រ៉ូប៊ឺត ពើទីត** បានធ្វើការនៅក្នុងនាទីជាសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសាលាក្ដីខ្មែរក្រហមនេះអស់រយៈពេលជាង៣ឆ្នាំ មកហើយ បន្ទាប់ពីត្រូវបានសម្រេចជ្រើសរើស និងបានស្បថចូលកាន់តំណែង កាលពីថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០៦ កន្លងទៅ។ លោក **ពើទីត** ធ្លាប់បំរើការងារនៅក្នុងវិស័យតុលាការនេះ អស់រយៈពេលជិត២០ឆ្នាំនៅក្នុងប្រទេសកាណាដា និងនៅប្រទេស មួយចំនួនទៀតដូចជាៈ ប្រទេសរ្វាន់ដា, ប្រទេសយូហ្គោស្លាវី, ប្រទេសសេរ៉ាឡេអូន និង ប្រទេសទីម័រខាងកើតជាដើម។

# ឌុច បកស្រាយឧក្រិដ្ឋកម្មនៅមន្ទីរស-២១

## Duch Describes Crimes Committed at S-21 Center



*ឌុច ក្នុងសវនាការ*

សំណុំរឿងកាត់សេចក្ដីទៅលើ អតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នៅតែបន្តធ្វើឡើងតទៅទៀត ដោយចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បញ្ហាដែលបានចោទសួរនៅក្នុងអំឡុងខែនេះ ភាគច្រើន គឺសំដៅទៅលើការចោទសួរពីសំណាក់ចៅក្រមសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទ **ឌុច** ដើម្បីរកឱ្យឃើញថា ជនជាប់ចោទរូបនេះពិតជាបានដឹងឮ និងអនុវត្ត ដោយផ្ទាល់នូវគោលនយោបាយនៅមន្ទីរស-២១ ដែលដាក់ចេញដោយ បក្សកុម្មុយនីស្ដកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជម្លោះប្រដាប់អាវុធដែលបានកើតឡើងរវាងកងទ័ពវៀតណាម និងពួកខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៨។

ជាគោលការណ៍ និងនីតិវិធីច្បាប់ដែលអនុវត្តន៍នៅក្នុងសាលាក្ដីពិសេសនេះ គោលដៅនៃការព្យាយាមលើកឡើងដោយមានទាំងការចោទសួរឱ្យឆ្លើយពីសំណាក់ជនជាប់ចោទ **ឌុច** ដើម្បីឆ្លុះបញ្ចាំងនូវឧក្រិដ្ឋកម្ម ដែលបានកើតឡើង និងទំនួលខុសត្រូវរបស់គាត់ ក្នុងឋានៈប្រធានមន្ទីរស-២១ ឬគុកទួលស្លែងជាទីដែលត្រូវបានសហព្រះរាជអាជ្ញាចោទថា មានអ្នកទោសចំនួនជាង ១២,៣៨០នាក់ ត្រូវបានគេធ្វើ ទារុណកម្មយ៉ាងសាហាវ សម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត ដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងឱ្យជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត។

កាលពីដើមខែមុន មានសាក្សី និងអ្នកជំនាញជាច្រើន បានលើកឡើងនូវសក្ខីកម្ម (ភស្ដុតាងជាសំដី) ជូនអង្គចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ ចំណែកឯនៅក្នុងខែនេះ ជនជាប់ចោទ **ឌុច** ត្រូវបានចោទសួរដោយចៅក្រមព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទៅលើឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្រោមការទទួលខុសត្រូវរបស់ **ឌុច** ជាពិសេសនៅគុកទួលស្លែង ជើងឯក និងគុកព្រៃស។ ជាក់ស្ដែងតាមការសង្កេតរបស់យើងដែលបានចូលរួមសង្កេតការណ៍នៅក្នុងសវនាការកាត់សេចក្ដីនេះ បង្ហាញថា ភាគច្រើន សក្ខីកម្ម ឬចម្លើយដែលជនជាប់ចោទរូបនេះជំរាបជូនអង្គសវនាការ គឺថាគាត់នៅតែរក្សាជំហរថា ការបំពេញតួនាទីរបស់គាត់នៅមន្ទីរស-២១ គឺ ដោយសារគាត់ធ្វើតាមបញ្ជាថ្នាក់លើរបស់គាត់ ដែលគាត់តែងតែនិយាយយោងនោះ គឺលោក **សុន សេន** (ស្លាប់, ធ្លាប់ជាអតីតឧនាយករដ្ឋមន្ត្រី-ទទួលបន្ទុកក្រសួងការពារជាតិ) និងលោក **នួន ជា** (អតីតប្រធានសភា និងកំពុងជាប់ឃុំខ្លួនបណ្ដោះអាសន្ននៅសាលាក្ដីខ្មែរក្រហម)។

អតីតប្រធានគុកទួលស្លែង **ឌុច** បានបញ្ជាក់ប្រាប់ទៅកាន់អង្គចៅក្រមថា គាត់ធ្វើតាមបញ្ជារបស់ថ្នាក់លើក្នុងការអនុវត្តន៍នូវ គោលនយោបាយរបស់បក្សនៅមន្ទីរស-២១។ ដូចនេះមានន័យថា ទាក់ទិននឹងចំណុចនេះ **ឌុច** ហាក់ដូចជាមិនបដិសេធនូវការទទួលខុសត្រូវរបស់ថ្នាក់លើរបស់គាត់ ដែលបញ្ជាឱ្យ

អនុវត្តគោលនយោបាយ ក្នុងការប្រព្រឹត្តបែបអមនុស្សធម៌នៅមន្ទីរ ស-២១ និងជនជាប់ចោទរូបនេះ នៅតែបញ្ជាក់នូវវិប្បដិសារីរបស់គាត់ចំពោះការដែលគាត់មិនចាត់វិធានការទប់ស្កាត់នូវអំពើទារុណកម្ម ការកាប់សម្លាប់អ្នកទោស ដោយកម្មាភិបាលថ្នាក់ក្រោមរបស់គាត់។ ចំណែកឯរឿងរ៉ាវទាក់ទិននឹងជម្លោះប្រដាប់អាវុធរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពវៀតណាម នោះ **ឌុច** ហាក់ដូចជាបដិសេធថា គាត់មិនបានដឹងច្បាស់លាស់ទេ ហើយថា គាត់ក៏មិនបានដឹងអំពីច្បាប់អន្តរជាតិ ដែលមានសំរាប់គ្រប់គ្រងទៅលើការប្រព្រឹត្តចំពោះអ្នកទោសសង្គ្រាម ជនជាតិវៀតណាមនោះផងដែរ។

**ការចូលបំភ្លឺរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក **វ៉ាន់ ណាត** ដែលជាសាក្សី និងជាអ្នកនៅរស់រានមានជីវិតពីគុកទួលស្លែង បានឡើងផ្តល់សក្ខីកម្ម (ភស្តុតាងជាសំដី) ជូនអង្គសវនាការដោយបានរៀបរាប់នូវឧក្រិដ្ឋកម្ម ដែលលោកបានទទួល និងបានដឹងឮដែលបានកើតឡើងនៅក្នុងគុកទួលស្លែង។ លោកគឺជាអ្នកគូររូបម្នាក់ ដែលបានបង្ហាញការចាប់អារម្មណ៍នូវទុក្ខសោករបស់លោកថា នៅក្នុងរយៈកាលដែលនៅក្នុងមន្ទីរឃុំខ្លួនទួលស្លែងនោះ លោកបានឃើញទិដ្ឋភាពដ៏សែនអមនុស្សធម៌។ លោកបានរៀបរាប់ ប្រាប់អង្គចៅក្រមថា: *"យើងឃ្លានណាស់ យើងហូបសត្វល្អិតដែលធ្លាក់ពីពិដាន។ យើងហូបនៅជិតនឹងសាកសពដែលនៅជិតនោះ ហើយយើងក៏មិនចាប់អារម្មណ៍ពីរឿងនោះដែរ ពីព្រោះ យើងដូចជាសត្វធាតុយ៉ាងដូចនោះដែរ។"*



*ជនរងគ្រោះ ជុំ ម៉ី នៅក្នុងសវនាការ*

ចំណែកឯលោក **ជុំ ម៉ី** ដែល ជាអ្នករស់រានមានជីវិតម្នាក់ទៀតពីគុកទួលស្លែង និងជាដើមបណ្តឹងរដ្ឋប្បវេណី បានឡើងមកបំភ្លឺតុលាការថា គាត់បានរងនូវការឈឺចាប់យ៉ាងខ្លាំងនៅក្នុងកំឡុងពេលដែលពួកខ្មែរក្រហម ចាប់បញ្ជូនគាត់ដាក់ក្នុងគុកទួលស្លែងដោយបានរងនូវការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។ លោកបានបន្តនិយាយថាលោកត្រូវបានកម្មាភិបាលខ្មែរក្រហមចោទប្រកាន់ថា ជាភ្នាក់ងារស៊ីអាយអេ (CIA) ឬជាកាហ្សេបេ (KGB) ដូចនេះ លោកត្រូវបានពួកគេធ្វើទារុណកម្មបង្ខំឱ្យសារភាព ដូចជា វាយនឹងដំបង, ឆក់នឹងខ្សែភ្លើង, ដកក្រចក ជាដើម។ លោក បានរៀបរាប់ថា ពួកខ្មែរក្រហមបានប្រើវិធីសាស្ត្រក្តៅមកលើគាត់។

លោក **ប៊ូ ម៉េង** អាយុ ៦៨ឆ្នាំ ក៏ជាអ្នកដែលនៅរស់រានមានជីវិតពីគុកទួលស្លែង និងក៏ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី បានចូលបំភ្លឺដល់អង្គសវនាការនេះដែរ។ លោកបានរៀបរាប់ថា លោកធ្លាប់ជាអ្នកគូររូបនៅក្នុងគុកទួលស្លែងនោះដែរ គឺ ជនជាប់ចោទ **ឌុច** ឱ្យគាត់គូររូបហូជីមិញ ដោយមាន ឌុច នៅអង្គុយជាប់នោះ។ អ្វីជាមន្ទិលរបស់លោកគឺថា ហេតុអ្វីបានជាគាត់ត្រូវបានពួកខ្មែរក្រហមចាប់យកមកដាក់ក្នុងគុកទួលស្លែងនេះ។ ចំពោះ លោក **ប៊ូ ម៉េង** ***"យុត្តិធម៌ដែលមានត្រឹមតែ ៥០ ទៅ ៦០% គឺមានវាមានន័យចំពោះលោកហើយ"***។ ដូចនេះលោក សូមឱ្យតុលាការកាត់ទោសប្រកបដោយភាពយុត្តិធម៌ផងចុះ។

នៅក្នុងអំឡុងដើមខែកក្កដានេះដែរ លោក **នង ចាន់ផល** ដែលបានអះអាងថា ជាអតីតកុមារដែលនៅរស់រានមានជីវិតនៅមន្ទីរ ស-២១ នេះ ក៏បានត្រូវតុលាការកោះអញ្ជើញមកធ្វើសាក្សីផងដែរ។ លោក **នង ចាន់ផល** អាយុ ៣៩ឆ្នាំ បាននិយាយប្រាប់ចៅក្រមថារូបគាត់ និងប្អូនប្រុសត្រូវបានបំបែកពីម្តាយរបស់គាត់ បន្ទាប់ពីម្តាយគាត់ត្រូវបានបញ្ជូនយកដាក់ឃុំនៅក្នុងមន្ទីរស-២១។ ប៉ុន្តែ សាក្សីរូបនេះត្រូវបានជនជាប់ចោទ ឌុច បដិសេធនូវសក្ខីកម្មរបស់គាត់ ដោយ ឌុច បានបំភ្លឺតបទៅវិញថា ជាគោលនយោបាយនៅមន្ទីរស-២១ កុមារទាំងអស់ត្រូវបានគេយកទៅកំទេចអស់ហើយ ដូចនេះ មិនមានកុមារនៅរស់រានមានជីវិតដូចការនិយាយរបស់សាក្សីនេះឡើយ។

និយាយជារួមមក សវនាការកាត់សេចក្តីទៅលើ **ឌុច** រហូតមកដល់ពេលនេះ នៅតែបន្តធ្វើហើយអាចរហូតទៅដល់ដើមខែតុលាខាងមុខនេះ ដោយសារនៅមានសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញសំខាន់ៗដែលពាក់ព័ន្ធជាច្រើនទៀតត្រូវចូលខ្លួនមកបំភ្លឺ។ ដូចនេះ ការដែលដំណើរការបែបនេះ មិនអាចកំណត់ថា តុលាការពិសេសនេះកាត់សេចក្តីយឺតនោះទេ ប៉ុន្តែដើម្បីធ្វើយ៉ាងណាឱ្យការកាត់សេចក្តី និងភស្តុតាងដាក់បន្ទុក និងដោះបន្ទុកត្រូវបានបកស្រាយ និងបំភ្លឺឱ្យបានពេញលេញ។

ម្យ៉ាងទៀត ទោះបីជានៅក្នុងសវនាការជាញឹកញាប់ ជនជាប់ចោទ **ឌុច** តែងតែនិយាយថាគាត់សោកស្តាយ និងមានវិប្បដិសារីចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង នៅមន្ទីរស-២១ និងថា គាត់សុខចិត្តទទួលសារភាពនូវទោសកំហុសនេះក៏ដោយ ក៏ប៉ុន្តែការដែលគ្រាន់តែឆ្លើយសុំទោស និងសារភាពនូវទោសកំហុស ដែលបានកើតឡើងដោយជនជាប់ចោទបែបនេះមិនទាន់គ្រប់គ្រាន់ឡើយ ពីព្រោះថា ចៅក្រម និងសាធារណជន ត្រូវការចង់ដឹងឱ្យកាន់តែច្បាស់ជាងនេះ ទៅទៀតអំពីមូលហេតុ ដែលនាំឱ្យមានឧក្រិដ្ឋកម្មដ៏សែនព្រៃផ្សៃកើតឡើងនៅគុកទួលស្លែងជាពិសេស និង អំពើកាប់សម្លាប់ ដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជានៅក្នុងសម័យខ្មែរក្រហមនោះ។

# អាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## Marriages under the Democratic Kampuchea (1975-1979)

ជាទូទៅការរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យបុគ្គល ម្នាក់ៗមិនអាចជ្រើសរើសគូស្រករតាមចិត្ត ឬមនោសញ្ចេតនា របស់ខ្លួនបានឡើយ។ ការរៀបការត្រូវប្រព្រឹត្តឡើងជាច្រើនគូក្នុងពេលតែមួយដែលមានចាប់ពី ៣គូ ៥គូ ២០-៣០គូ ឬលើសពីនេះទៅទៀត អាស្រ័យទៅតាមទំហំនៃការគ្រប់គ្រងរបស់កន្លែងនីមួយៗ ហើយ ប្រព្រឹត្តក្នុងរយៈពេលប្រហែលជាពីរ-បីម៉ោងប៉ុណ្ណោះ។ ការរៀបការរបៀបនេះអង្គការរបស់ខ្មែរក្រហមយល់ថា កុំឱ្យខាតពេលវេលា ឥតប្រយោជន៏ក្នុងការបង្កបង្កើនផល។ គ្មានទេ វត្តមានសាច់ញាតិ មិត្តភ័ក្ដិជិតស្និទ្ធ ឬភ្ញៀវកិត្តិយស ហើយគ្មានទេការជប់លៀង ភ្លេងកំដរ ឬទំនៀមទម្លាប់ តាមប្រពៃណីជាតិឡើយ។

ផ្ទុយទៅវិញភាគច្រើនលើសលប់ គូស្រករដែលត្រូវរៀបការនោះមិនដែលបានស្គាល់គ្នានោះទេ។ មានមនុស្សតិចតួចបំផុតដែលអង្គការយល់ស្របតាមការស្នើសុំទៅលើបុគ្គលដែលខ្លួនចង់រៀបការជាមួយនោះបាន ដោយពួកគេធ្លាប់ជាអ្នកតស៊ូ ដើម្បីបដិវត្តន៍ជាអតីតយុទ្ធជនជាដើម។ ទោះភាគីម្ខាងទៀតនោះមិនបានយល់ព្រមក៏ដោយ។ មានអ្នកខ្លះប្រកែកទៅនឹងការរៀបការនោះដែរ តែត្រូវរងនូវការកៀបសង្កត់ផ្សេងៗដូចជា ការស្នើឱ្យទៅរៀនសូត្រលត់ដំការងារបន្ថែមជាដើម។ ដូច្នេះពួកគេត្រូវតែយល់ព្រម ឬ ទទួលយកតាមការសម្រេចពីអង្គការ។

នាពេលកន្លងមក អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានធ្វើគំរោងសិក្សាស្រាវជ្រាវមួយអំពីអំពើហិង្សានៅក្នុងសម័យខ្មែរក្រហម ដែលក្នុងនោះក៏មានការសាកសួរសំភាសន៍ ជនរងគ្រោះនៃរបបខ្មែរក្រហមផងដែរ។ នារីម្នាក់ដែលត្រូវបានសំភាសន៍នាពេលនោះ បានរៀបរាប់នូវបទពិសោធន៏របស់គាត់ទាក់ទិននឹងអាពាហ៏ពិពាហ៏ នាសម័យខ្មែរក្រហម។ **នាង ថាវី** និយាយថា *ពីដំបូងនាងមិនចង់រៀបការទេ តែនាង ខ្លាចផលវិបាកផ្សេងៗ។ នាងបានរៀបរាប់ថា:* ***"ខ្ញុំបានប្រកែកដែរ តែគេថា បើខ្ញុំមិនព្រម គេបង្ខំឱ្យខ្ញុំទៅជីកដីលើកទំនប់នៅទីឆ្ងាយ ឬគេយកមនុស្សទៅចងអូសតាមសេះ ខ្ញុំខ្លាចពេក ខ្ញុំក៏ព្រមរៀបការទៅ"*** ។

នៅពេលគូស្រករដែលត្រូវរៀបការ គេតម្រូវឱ្យឡើងប្ដេជ្ញា ដូចជា "ការខិតខំធ្វើការឱ្យបានសម្រេចតាមផែនការកំណត់របស់អង្គការបង្កើតកូនឱ្យអង្គការជាដើម"។ ក្រោយពីការរៀបការរួច ពួកគេអាចរស់នៅជាមួយគ្នាបានត្រឹមរយៈពេលពីរ-បីថ្ងៃ ប៉ុណ្ណោះបន្ទាប់មកពួកគេត្រូវត្រឡប់ទៅធ្វើការនៅអង្គភាពផ្សេង រៀងៗខ្លួនរបស់ពួកគេ។ នៅក្នុងអំឡុងពេលនៃការរស់នៅជាមួយគ្នា រយៈពេលពីរ-បីថ្ងៃ នេះ ពួកគេអាចស្ថិតក្រោមការតាមដានពីអង្គការ "ឈ្លប" ថាតើពួកគេមានការចុះសម្រុងនឹងគ្នាឬទេ។ បើពួក គេមិនចុះ សម្រុងនឹងគ្នាទេមានន័យថា: ពួកគេមិនគោរពតាមការចាត់តាំងរបស់អង្គការ អាចត្រូវទទួលការកៀបសង្កត់ផ្សេងៗ និងអាចចាត់ទុកថា ក្បត់បដិវត្តន៏ទៀតផង។

បុរសម្នាក់ទៀត ដែលក្រុមការងារស្រាវជ្រាវបានសាកសួរក៏បានផ្ដល់នូវមតិប្រហាក់ប្រហែលគ្នាដែរ អំពីអាពាហ៏ពិពាហ៏នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្ដែង គឺ **លោក សុផុន** ដែលត្រូវគេបង្ខំឱ្យរៀបការក្រោយពីបានបដិសេធ ២ដង បាននិយាយថា: *"ក្រោយរៀបការរួចឈ្លបមកតាមដានមើលយើង ថាតើយើងគេងជាមួយគ្នាឬអត់ បើអត់គេយកយើងទៅកសាង។ យើងគេងជាមួយគ្នាដោយសារខ្លាចអង្គការ"*។

ជនរងគ្រោះអំពើហិង្សាផ្លូវភេទរវាងឆ្នាំ១៩៧៥-១៩៧៩ សូមទាក់ទង: អង្គការអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

អាសយដ្ឋានៈ ផ្ទះ១២ ផ្លូវ២៨២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ទូរស័ព្ទ: ០២៣ ៧៣០ ០៣២ ឬ ០១២ ៩១៤ ៩៣២។

### ព័ត៌មានសំខាន់:

➤ ប្រសិនបើលោកអ្នកចាប់អារម្មណ៏ចង់ចូលរួមដាក់ពាក្យបណ្ដឹង**ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្ដីខ្មែរក្រហម**

**សូមទាក់ទង:**

- **សមាគមអាដហុក (ADHOC)**
  លេខទូរស័ព្ទ: ០២៣ ៩៩០ ៥៤៤, ០២៣ ២១៨ ៦៥៣
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID)
  លេខទូរស័ព្ទ: ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD)
  លេខទូរស័ព្ទ: ០២៣ ៣៦៤ ៧៣៥
- អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA)
  លេខទូរស័ព្ទ: ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១

➤ ស្ដាប់កម្មវិធីឃ្លាំមើលសាលាក្ដីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➤ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ www.krtrial.info

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(NED) និង ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**

NED The National Endowment for Democracy
Supporting freedom around the world

ded
Deutscher Entwicklungsdienst